គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ក្រេឌីត

CREDIT MICROFINANCE INSTITUTION

*ធ្វើឲ្យជីវភាពធូរធារ*

**គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុក្រេឌីត** ជាគ្រឹះស្ថាន គ្រឹស្ទាន ដែលបានចាប់បដិសន្ធិពីអង្គការសង្គ្រោះពិភពលោកកម្ពុជា នៅឆ្នាំ១៩៩៣ ក្នុងគោលបំណងផ្តល់សេវាកម្មហិរញ្ញវត្ថុច្រើនប្រភេទ ដូចជា ផ្តល់ប្រាក់កម្ចី និងប្រាក់សន្សំ ជូនដល់ប្រជាជនក្រីក្រ និងសហគ្រិនតូចៗ ដើម្បីចូលរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចជនបទក្នុងប្រទេសកម្ពុជា។ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុក្រេឌីត ទទួលបានអាជ្ញាប័ណ្ណអចិន្ត្រៃយ៍ជាផ្លូវការពីធនាគារជាតិ នៅក្នុងឆ្នាំ២០០៧ ហើយបច្ចុប្បន្នក្រេឌីតមានម្ចាស់ភាគទុនិកធំៗ ចំនួន៣ ដូចជា សង្គ្រោះពិភពលោក សហរដ្ឋអាមេរិក សង្គ្រោះពិភពលោកកាណាដា និងឱកាសអន្តរជាតិ។ សព្វថ្ងៃ ក្រេឌីត ជាគ្រឹះស្ថានមាននិរន្តភាពនិងរីកចំរើនឥតឈប់ឈរហើយកំពុងប្រតិបត្តិការនៅតាម បណ្តាខេត្តក្រុង ដូចជា ភ្នំពេញ កណ្តាល កំពង់ចាម ត្បូងឃ្មុំ កំពង់ឆ្នាំង ព្រៃវែង បាត់ដំបង សៀមរាប តាកែវ កំពង់ស្ពឺ និងពោធិ៍សាត់។

# ដំណឹងជ្រើសរើសបុគ្គលិក

ដើម្បីឆ្លើយតបតាមការរីកចំរើនព្រមទាំងការពង្រីកតំបន់ប្រតិបត្តិការបន្ថែម ក្រេឌីតត្រូវការជ្រើសរើសបុគ្គលិកសំរាប់បំរើការងារនៅសាខាសំរាប់មុខតំណែងដូចខាងក្រោមៈ

១. អ្នកបើកបរ (Driver) ១នាក់ សំរាប់សាខាខេត្តតាកែវ

កាលបរិច្ឆេទឈប់ទទួលពាក្យ : ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១០ វេលាម៉ោង ១២:០០ រសៀល
កាលបរិច្ឆេទចេញឈ្មោះសំរាំង : បេក្ខជនត្រូវមកមើលបញ្ជីឈ្មោះចូលប្រឡងនៅ ថ្ងៃទី៣ ខែសីហា ឆ្នាំ២០១០ វេលាម៉ោង ៣:០០ រសៀល នៅតាមការិយាល័យដែលបានដាក់ពាក្យ

## ១. គុណវុឌ្ឍិជាអ្នកបើកបរ

- ត្រូវមានសញ្ញាបត្រប្រឡងជាប់មធ្យមសិក្សាទុតិយភូមិ
- ត្រូវគាំទ្រដោយឥតងាករេទូវទស្សនៈវិស័យ និង បេសកកម្មរបស់ក្រេឌីត
- ស្មោះត្រង់ មានប្រវត្តិរូបល្អ អាកប្បកិរិយាល្អ រួសរាយរាក់ទាក់តែមានលក្ខណៈហ្មត់ចត់ និង ប្រាកដប្រជា ។
- មានជំនាញក្នុងការប្រាស្រ័យទាក់ទងទាំងមជ្ឈដ្ឋានខាងក្នុង និង មជ្ឈដ្ឋានខាងក្រៅ
- មានជំនាញក្នុងការបើកបរ និង មានប័ណ្ណបើកបរសុពលភាពដែលចេញដោយក្រសួងសាធារណៈការ
- មានចំណេះដឹងចំពោះច្បាប់ចរាចរ និង ផ្លាកសញ្ញាចរាចរ
- មានសមត្ថភាពក្នុងការជួសជុលរថយន្ត និង ការថែរទាំរថយន្ត
- ធ្លាប់មានបទពិសោធន៍ក្នុងមុខតំណែងយ៉ាងហោចណាច់ ០១ ឆ្នាំ ជាមួយក្រុមហ៊ុន ឬអង្គការ ។

ក្រេឌីត ផ្តល់ជូនបុគ្គលិកពេញសិទ្ធិនូវប្រាក់បៀវត្សដែលស្របតាមទីផ្សារការងារ ការអប់រំ បទពិសោធនការងារ និងសក្តានុពលរបស់បុគ្គលិក។ ក្រៅពីប្រាក់បៀវត្ស ក្រេឌីតផ្តល់ជូនអត្ថប្រយោជន៍ផ្សេងៗ ដូចជាៈ

១- ប្រាក់រង្វាន់ៈ ប្រចាំខែ ប្រចាំឆ្នាំ និងប្រាក់ខែទី១៣
២- ការធានារ៉ាប់រងៈ លើជីវិត និងគ្រោះថ្នាក់
៣- ប្រាក់សោធននិវត្តន៏ៈ ប្រាក់បំណាច់ពេលបុគ្គលិកចូលនិវត្តន៏ ឬលាលែងពីការងារ
៤- ប្រាក់សុខភាពៈ ប្រចាំឆ្នាំ និងអាចចំណាយលើគ្រួសារបាន
៥- ការឈប់សំរាកសាធារណៈ និងការឈប់សំរាកប្រចាំឆ្នាំៈ ស្របតាមច្បាប់ការងារ
៦- ថ្ងៃបំពេញការងារៈ ៥ថ្ងៃក្នុងមួយសប្តាហ៏
៧- ផ្តល់ប្រាក់កម្ចីសំរាប់បុគ្គលិកពេញសិទ្ធិៈ ស្ថាបន័គិតអត្រាការប្រាក់ពិសេស
៨- ឯកសណ្ឋានៈ សំរាប់បំពេញការងារ
៩- ការហ្វឹកហ្វឺនបំពាក់បំប៉នៈ សម្ភារៈបំពេញការងារ ត្រូវបានផ្តល់ជូនពីគ្រឹះស្ថានទាំងអស់ ។ល។

បេក្ខជន-បេក្ខនារីដែលមានចំណាប់អារម្មណ៏ សូមយកប្រវត្តិរូបនិងពាក្យសុំធ្វើការដោយភ្ជាប់មកជាមួយនូវរូបថត (៤X៦) ថតថ្មីចំនួន ២សន្លឹក អត្តសញ្ញាណប័ណ្ណថតចំលង ១ច្បាប់ សៀវភៅគ្រួសារថតចំលង ១ច្បាប់ សញ្ញាបត្រ និងព្រឹត្តបត្រពិន្ទុថតចំលង ១ច្បាប់ (បញ្ជាក់ពីសាលាខេត្ត/ក្រុង) ព្រមទាំងរាល់វិញ្ញាបនបត្រជំនាញផ្សេងៗ ដែលបេក្ខជន បានសិក្សា ប័ណ្ណសរសើរ និងវិញ្ញាបនបត្របញ្ជាក់ការងារ (ប្រសិនបើបេក្ខជនធ្លាប់បំពេញការងារពីមុន)។

**តាមអាសយដ្ឋាន** ការិយាល័យកណ្តាលៈ ផ្ទះលេខ៧១ ផ្លូវលេខ១៦៣ សង្កាត់ទួលស្វាយព្រៃ១ ខណ្ឌចំការមន រាជធានីភ្នំពេញ ឬតាមការិយាល័យដែលកំពុងធ្វើការ។
សាខា តាកែវៈ ភូមិផ្សារតាកោ សង្កាត់រកាក្នុង ក្រុងដូនកែវ ខេត្តតាកែវ

ព័តិមានបន្ថែម បេក្ខជន-បេក្ខនារី អាចសាកសួរនៅតាមការិយាល័យសាខាដែលខ្លួនបានដាក់ពាក្យ ឬអាចបើកមើលតាមវេបសាយៈ www.credit.com.kh ។